# ស្នេហា ជាអ្វី?



ខ្ញុំជឿថាអ្នកគ្រប់គ្នាដឹងថាស្នេហាជាអ្វី ទោះជាបានសួរពិភាក្សាគ្នាអំពីសំណួរនេះជាញយដងដដែលៗក៏ដោយ ។ហេតុអី?ព្រោះស្នេហា ស្មុគស្មាញជាពិសេស មកពីវាច្រើនកើតមានឡើងពីខួរក្បាលឬកាមតណ្ហា ជាជាងពីបេះដូងស្មោះ។ស្នេហា តាមន័យត្រង់គឺការស្រលាញ់ស្អិត ឬជាប់ស្អិតដែលគ្មាននរណាងាយនឹងបេះផ្តាច់ចេញឬបំបែកចេញបានពីអ្វីឬអ្នកដែលខ្លួនស្រលាញ់បានឡើយ។បើបេះចេញបាន នោះក៏នឹងបន្សល់នូវទឹកភ្នែកឬការនឹកគិតដែលជួនកាលអាចនាំដល់ការធ្វើអត្តឃាតទៀតក៏មានដែរ។ស្នេហាគឺពិតណាស់ជាការស្រលាញ់ដោយប៉ងប្រាថ្នា មិនមែនស្រលាញ់ហើយមិនប៉ងប្រាថ្នានោះទេមានន័យថាចង់បាននូវអ្វី ឬ អ្នកណាដែលខ្លួនស្រលាញ់ ។មនុស្សដែលខ្លួនស្រលាញ់ ខ្លួនឯងគិតថាស្អាតល្អ លើសគេ ៖ ត្រង់ហ្នឹងគួរដឹងថា បវរកញ្ញា បវរបុរស ឬប្រុសស្រីនានាដែលស្អាតល្បីនាមពេញពិភពលោកនេះក្តីក៏មិនអាចធៀបបានឡើយនឹងអ្វី ឬនរណាដែលខ្លួនស្រលាញ់ស្អិតជាប់បេះដូងនោះ។ប៉ុន្តែស្នេហាមិនបានន័យថាត្រូវតែបានទទួលការស្រលាញ់តបវិញនោះទេ ។ចឹងហើយស្នេហាមានន័យសំខាន់ចំពោះអ្នកស្រលាញ់ជាងអ្នកដែលត្រូវបានស្រលាញ់។ប៉ុន្តែគួរអោយអនិច្ចារដែលស្នេហាភាគច្រើនតែងមានវិបត្តិព្រោះថាស្នេហា ដែលពិតជាត្រូវការមនុស្សពីរនាក់ស្រលាញ់គ្នាទៅមកបង្កភាពស្មុគស្មាញ ដោយសង្គមព្រោះស្នេហាមិនប្រាកដថានឹងបានទទួលនូវការស្រលាញ់តបវិញនោះទេ ។ត្រង់ហ្នឹងហើយ ដែលចេះតែមានការកើតសេចក្តី សោកសៅ ហ្មងសៅនៅក្នុងរឿងស្នេហាជាពិសេសស្នេហាយុវវ័យដែលដែលតែងខកចិត្តនិងបន្សល់នូវទឹកភ្នែក ហើយបណ្តាលអោយកវីអ្នកនិពន្ធចំរៀងតែងរឿងរ៉ាវស្នេហាមិនចេះជិនណាយពីជំនាន់មួយទៅជំនាន់មួយ។ទោះជាស្នេហាមិនបានទទួលនូវការស្រលាញ់តបវិញក៏ដោយ ប៉ុន្តែអ្នកស្រលាញ់នៅតែស្រលាញ់ពីព្រោះស្នេហាផ្តើមដោយអ្នកស្រលាញ់មិនមែនដោយអ្នកដែលត្រូវបានគេស្រលាញ់នោះទេ ។ដូច្នេះបានមនុស្សទូទៅចូលចិត្តស្រលាញ់គេជាជាងត្រូវបានគេស្រលាញ់។ c`est pourquoi la plupart des gens préfèrent aimer que d`être aimé.